**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ: ០២០/២១ ក.ប/សរ.ណ.ល.ក.ខ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រើប្រាស់ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក សម្រាប់រោងចក្រ សហគ្រាស និងសិប្បកម្ម ដែលស្ថិតក្នុង "តំបន់លឿង"

យោងប្រការ៦ នៃសេចក្តីសម្រេចលេខ៥៤សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសូមជូនដំណឹងដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម និងអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិកទាំងអស់ ដែលស្ថិតក្នុង "តំបន់លឿង" នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ជ្រាបថា លោក លោកស្រី អាចស្នើសុំ "**ប័ណ្ណអនុញ្ញាតដឹកជញ្ជូនកម្មករនិយោជិត**" (ដូចមានក្នុងឧបសម្ព័ន្ធ) តាមកម្មវិធី https://transportationpass.mlvt.gov.kh។

លោក លោកស្រី នឹងទទួលបានប័ណ្ណអនុញ្ញាតជាទម្រង់ឌីជីថល ក្នុងរយៈពេល ១ថ្ងៃ បន្ទាប់ពីការស្នើសុំ និងបំពេញព័ត៌មានបានត្រឹមត្រូវ។

ទន្ទឹមនឹងនេះ ដើម្បីបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ច នៅរៀងរាល់ពេលធ្វើដំណើរទៅកន្លែងធ្វើការ និងត្រឡប់មកផ្ទះ លោក លោកស្រី ត្រូវយកតាមខ្លួននូវ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់អ្នកផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិក។
- កាតសម្គាល់កម្មករនិយោជិត ឬប័ណ្ណសមាជិក ប.ស.ស. ចំពោះការប្រើប្រាស់យានយន្តផ្ទាល់ខ្លួនកម្មករនិយោជិតម្នាក់ៗ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមក្រុមតេឡេក្រាម https://t.me/transportationpass។

ក្រសួងមានសេចក្តីជឿជាក់ថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងសិប្បកម្ម និងអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិត និងបុគ្គលិកទាំងអស់ដែលស្ថិតក្នុង "តំបន់លឿង" នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ពុធ ២រោច ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- គណៈកម្មការជាតិ គ.ប.ខ.
- រដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្តាល "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# បណ្ណអនុញ្ញាតដឹកជញ្ជូន
# កម្មករនិយោជិត

រូបថត

## សម្រាប់ចម្ងាយ

**ផ្លូវពី ............................ ទៅ ....................................**

**ស្លាកលេខរថយន្ត ឬយានយន្ត ....................................**

- ឈ្មោះ ...................................... ភេទ........ លេខទូរស័ព្ទ ....................
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ..............................................
- ចំនួនកម្មករនិយោជិតត្រូវដឹក ......... នាក់
- ឈ្មោះរោងចក្រ/សហគ្រាស/អាជីវកម្ម ..............................................

..............................................................................................

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

QR Code

**អ៊ិត សំហេង**

លេខ 00001 / ប.ម.ត

*សម្គាល់៖ ចំពោះការប្រើប្រាស់យានយន្តផ្ទាល់ខ្លួន កម្មករនិយោជិតម្នាក់ៗ ត្រូវយកភ្ជាប់តាមខ្លួននូវកាតសម្គាល់កម្មករនិយោជិត ឬប័ណ្ណសមាជិក ប.ស.ស.*

**ហាមធ្វើដំណើរចេញចូល និងឆ្លងកាត់តំបន់ក្រហម និងតំបន់លឿងទុំ**

*សមត្ថកិច្ចអាចស្កេន QR CODE ដើម្បីបញ្ជាក់*

**ប័ណ្ណអនុញ្ញាតនេះ មានសុពលភាពត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១**

# បណ្ណអនុញ្ញាតដឹកជញ្ជូន
# កម្មករនិយោជិត

## សម្រាប់ចម្ងាយ

## ផ្លូវពី ............................ ទៅ ................................

## ស្លាកលេខរថយន្ត ឬយានយន្ត ..............................................

- ឈ្មោះ ................................... ភេទ........ លេខទូរស័ព្ទ .....................
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ..............................................
- ចំនួនកម្មករនិយោជិតត្រូវដឹក ......... នាក់
- ឈ្មោះរោងចក្រ/សហគ្រាស/អាជីវកម្ម ..................................................

..................................................................................................

*សម្គាល់៖ ចំពោះការប្រើប្រាស់យានយន្តផ្ទាល់ខ្លួន កម្មករនិយោជិតម្នាក់ៗ ត្រូវយកភ្ជាប់តាមខ្លួននូវកាតសម្គាល់កម្មករនិយោជិត ឬប័ណ្ណសមាជិក ប.ស.ស.*

**ហាមធ្វើដំណើរចេញចូល និងឆ្លងកាត់តំបន់ក្រហម និងតំបន់លឿងទុំ**

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២១

**ត.ប. រដ្ឋមន្ត្រី**

**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ធុល នាង**

QR Code

**គណ្ណាលេខ 00001 / ម.ជ.ត**

*សមត្ថកិច្ចអាចស្កេន QR CODE ដើម្បីបញ្ជាក់*

ប័ណ្ណអនុញ្ញាតនេះ មានសុពលភាពត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១